មជ្ឈមណ្ឌលឯកសារកម្ពុជា

**TKI0506**

**ម៉ោង ម៉ាច ភេទស្រី I00313**

**មុខងារៈ នារីពេទ្យ**

**សម្ភាសន៍ជាមួយ ម៉ោង ម៉ាច អាយុ៥០ឆ្នាំ ត្រូវជាម្ចាស់ប្រវត្តិរូប**

**រស់នៅភូមិព្រៃលៀប ឃុំព្រៃអំពក ស្រុកគិរីវង់ ខេត្តតាកែវ**

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០**

**សម្ភាសន៍ដោយ ហ៊ិន សុធានី និង រី លក្ខិណា**

០០:៤៥:៤៩

**២៤ទំព័រ**

ធានី ៖ ជម្រាបសួរមីងពួកខ្ញុំពីរនាក់ ខ្ញុំឈ្មោះធានី ហើយនឹងលក្ខិណា ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកនេះសុំអនុញ្ញាតិដូចថា សុំសម្ភាសន៍មីងយកបទសម្ភាសន៍យកចុះក្នុងទស្សនាវដ្តី ឬក៏សម្រាប់អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ ទុកឲ្យក្មេងៗក្រោយៗ ឬអ្នកស្រាវជ្រាវណាគេចង់សរសេរសៀវភៅសរសេរអីចឹង ។ តើមីងអនុញ្ញាតិឲ្យពួកថតជាសម្លេងអីចឹង ហើយនឹងបទសម្ភាសន៍របស់មីង យកទៅស្រាវជ្រាវបានទេ?

ម៉ាច ៖ មិនដឹងម៉េច ស្រេចប្អូនឯង មីងមិនដឹងម៉េចទេ និយាយលិចទៅកើត មិនសូវចេះនិយាយច្រើននឹងគេផង ។

ធានី ៖ អីចឹង សុំអត់ទោសមីងមានឈ្មោះអីដែរ?

ម៉ាច ៖ ត្រកូលម៉ង ម៉ោង ម៉ាច ។

ធានី ៖ ម៉ោង ម៉ាច?

ម៉ាច ៖ ចាស! ហ្នឹងហើយ ។

ធានី ៖ អាយុប៉ុន្មានឆ្នាំនឹង?

ម៉ាច ៖ ៥០គត់ហើយ ៤៩ ៥០គត់ ឆ្នាំឆ្លូវ ។

ធានី ៖ មីងមានស្រុកកំណើតនៅណា?

ម៉ាច ៖ ស្រុកកំណើតខ្ញុំនៅនឹង ។

ធានី ៖ ភូមិឃុំអីដែរ?

ម៉ាច : ភូមិព្រៃលៀប ឃុំព្រៃអំពក ស្រុកគីរីវង់ ខេត្តតាកែវហ្នឹងម៉ង ។

ធានី : ហើយឪពុកម្ដាយ ឪពុកឈ្មោះអី?

ម៉ាច : ម៉ោង មុំ គាត់ស្លាប់បាត់ហើយ ។

ធានី : ម្ដាយ គាត់ឈ្មោះអីដែរ?

ម៉ាច : ហូ យន់ ស្លាប់អស់ ។

ធានី : បងប្អូនប៉ុន្មាននាក់?

ម៉ាច : ...៥នាក់ ប្រុស២ ស្រី៣ នៅទាំងអស់ ។

ធានី : ចុះឪពុកម្ដាយមីងដែលគាត់ស្លាប់នឹង ស្លាប់នៅសម័យណា?

ម៉ាច : គាត់ទើបនឹងស្លាប់ ឪខ្ញុំស្លាប់ជំនាន់លន់ នល់ គេអាពតចូលនោះ គេបាញ់ គេប្លន់នោះ ស្លាប់កាលនឹងទៅឪ ហើយម៉ែខ្ញុំទើបនឹងស្លាប់ទេ ទើបបាន២ឆ្នាំនឹងទេ ។

ធានី : មីងដែលធ្លាប់បានចូលរៀនចូលអីនឹងគេទេ?

ម៉ាច : អត់ មិនដែលបានចូលនឹងគេទេ ។

ធានី : អត់ចូលរៀនទេ អក្សរអត់ចេះដែរ?

ម៉ាច : អក្សរអត់ចេះដែរ អត់ដែលបានរៀន កាលលន់ នល់ខ្ញុំធ្វើការ ហើយដល់ពេលអាពតមិនបានរៀនអីទេដល់សព្វថ្ងៃ ។

ធានី : អីចឹងសម័យលន់ នល់មីងនៅកូនក្មេង?

ម៉ាច : នៅតូច ។

ធានី : ដល់សម័យប៉ុលពតទើបនឹងពេញវ័យ?

ម៉ាច : ដល់មកអាពតពេញវ័យ១២-១៣នឹងពេញវ័យ ក៏អត់បានរៀន ។

ធានី : កាលឆ្នាំណាដែលសម័យប៉ុលពតចូលមកនឹង?

ម៉ាច : អឺ! មីងមិនចាំ មីងអត់ដឹងឆ្នាំទេ ដឹងថាកាលនឹងកើតមុនប៉ុលពត លន់ នល់អីចឹងពួចាស់ៗថាលន់ នល់ៗ ដល់លន់ នល់អីចឹងទៅ កាប៉ាល់ហោះក៏បាញ់ រថក្រោះក៏បាញ់ចូលសង្គម អាពតនឹងទៅ ។

ធានី : ម៉េចទៀតដល់ពេលសង្គមនឹងចូលមកដល់?

ម៉ាច : យើងមិនរត់ទៅ ក៏រត់ទៅៗស្រុកលើទៅហើយដាច់សង្វែង អត់បាយក្រហាយទឹកអីចឹងទៅ ចេះទៅហើយ មិនហ៊ាននៅៗណាបើយើងតែខ្លាច ។

ធានី : ខ្លាចអី?

ម៉ាច ៖ ខ្លាចអី បើគ្រាប់កាំភ្លើងដាក់សំរុក ។

ធានី ៖ មកពីណា?

ម៉ាច ៖ មកពីក្រោម ហើយយើងម៉េចហ៊ាននៅ ។

ធានី ៖ អត់ទេ ចង់សួរមីងថាពេលដែលសម័យខ្មែរក្រហមចូលមកដល់នៅភូមិនេះ តើភូមិនេះយ៉ាង ម៉េចដែរ ហើយពេលនឹងមីងនៅកន្លែងណា ហើយយើងធ្វើអី?

ម៉ាច ៖ កាលខ្មែរក្រហមចូល កាលនឹងយើងរត់ហើយបានខ្មែរក្រហមចូល ហើយបានយើងចុះពីលើមកនៅស្រុកវិញ ។

ធានី ៖ គេឲ្យត្រឡប់មកនៅស្រុកវិញ?

ម៉ាច ៖ ឲ្យមកស្រុកវិញ ។

ធានី ៖ ហេតុអីបានរត់ទៅ?

ម៉ាច ៖ ខ្ញុំរត់ទៅនៅបើខ្លាចៗគ្រាប់កាំភ្លើងគេបាញ់ គេថាម៉េចកាលនឹងគេថាកងទ័ពគេម៉េចយួនជាម៉េចចេះតែខ្លាចជិនាន់នឹង កាលនឹងយើងចូលប៉ុលពតហើយណា វេទនាម៉ាសារ២សារ វេទនារត់ ទម្រាំបានស្រួលបួល ។

ធានី ៖ វេទនាម៉េច?

ម៉ាច ៖ វេទនាយើងរត់ យើងចេះតែខ្លាច យើងអត់ដឹង យើងអត់ដឹងចេះតែខ្លាច ។

ធានី ៖ ចុះពេលណាដែលទៅធ្វើការ?

ម៉ាច ៖ ខ្ញុំនៅតូច តែម៉ែឪនាំរត់ទៅចេះតែទៅ ។

ធានី ៖ ចុះពេលណាមីងទៅធ្វើការ?

ម៉ាច ៖ អាពេលធ្វើការនឹងវា ។

ធានី ៖ មុននឹង មុនរត់នឹង?

ម៉ាច ៖ រត់ហើយ រត់ហើយៗបានមុនបំផុត ម្តងជា២ដង ហើយបានរត់ក្រោយចូលធ្វើការហើយ រត់សារមុននៅតូច អត់ទាន់អីទេ រត់ចេញពីស្រុកអត់ទាន់ចូលធ្វើការទេ គេមិនទាន់ហៅចូលធ្វើការទេ ដល់មកវិញបានស្រួលបួលបានគេហៅឈ្មោះចូលធ្វើការ ស្រេចមេភូមិប្រធានភូមិយើងនឹង ចូលធ្វើការនៅពេទ្យឃុំនឹងទៅ ។ ដល់ហើយរត់ម៉ាសារទៀត ដល់រត់ម៉ាសារទៀតអីចឹង អានឹងយើងសុទ្ធតែចាញ់ឃោសនាគេហើយ ។ នៅពេទ្យឃុំៗដំបូង គេយកទៅនៅពេទ្យភ្នំពេញនឹងម៉ង់អីចឹង ។ ហើយដល់បងប្អូនយើងប៉ុន្មានមកភាគេនឹង គេឲ្យ

ចេញៗ ម៉ោង៦ ចេញផុតពីទីក្រុងភ្នំពេញ ក៏ចាប់ផ្តើមចេញទៅខ្ញុំទៅនៅស្រុកបាត់ដំបងជិះរទេះភ្លើងទៅស្រុកបាត់ដំបង ។

ធានី : ខ្ញុំសួរបកក្រោយបន្តិចមកដល់កន្លែងនឹង ចង់និយាយថាពេលដែលមីងមកធ្វើការជាប្រធានភូមិនឹង អ្នកណាគេប្រធានភូមិ?

ម៉ាច : ស្លាប់បាត់ហើយ យាយអ៊ីម ។

ធានី : គាត់ឈ្មោះអីគេអ៊ីម?

ម៉ាច : មីងអ៊ីម ឪគាត់នឹងឈ្មោះអីតាអឹម យាយទេ ស្គាល់តែតាអ៊ីម មិនដឹងឪវាឈ្មោះអីឥឡូវ គាត់ស្លាប់បាត់ហើយ ។

ធានី : គាត់នឹងអ្នកឲ្យមីងទៅធ្វើការ?

ម៉ាច : ហ្នឹងហើយ គាត់ប្រធានភូមិ ឥឡូវគាត់ស្លាប់បាត់ហើយ ។

ធានី : ចាំឆ្នាំទេមីង កាលនឹងមីងអាយុប៉ុន្មានគេឲ្យទៅធ្វើការ?

ម៉ាច : អាយុ១៣ មិនដឹងឆ្នាំអីទេ មិនសូវចេះដឹងឆ្នាំទេ ចាំទេ ។

ធានី : ពេលនឹងមីងអាយុ១៣ឆ្នាំបានគេ?

ម៉ាច : ហ្នឹងហើយដឹងថាអាយុ១៣ខ្លួនឯង ។

ធានី : បានប្រធានភូមិឲ្យមីងទៅធ្វើពេទ្យឃុំនឹង?

ម៉ាច : ចាស! ធ្វើពេទ្យឃុំ អាយុ១៣ហ្នឹង ។

ធានី : ហើយអ្នកណាគេខ្លះទៅជាមួយមីង?

ម៉ាច : ច្រើនដែល២-៣នាក់ ប៉ុនឥឡូវស្លាប់បាត់អស់ហើយ អត់ឃើញផង អត់ចាំដែលនៅភូមិនឹង២-៣នាក់ ប៉ុនឥឡូវមិនឃើញមកនៅស្រុកណា ខ្លះស្លាប់ ។

ធានី : ឈ្មោះអីខ្លះ?

ម៉ាច : គឿៗមួយវាទៅនៅមណ្ឌលគិរីណា ។

ធានី : គឿនឹង ស្អីគេគឿ?

ម៉ាច : គឿនឹង យាយម៉ែគេទីវ ទីវ គឿ ។

ធានី : ឈ្មោះអីទីវ?

ម៉ាច : ទីវ គឿ ឥឡូវគេមានប្តីនៅមណ្ឌលគិរីនោះ ។

ធានី : ហើយអ្នកណាគេទៀតមីង?

ម៉ាច : ហ្នឹងធ្វើការជាមួយខ្ញុំដែរ ហើយមានអ្នកស្លាប់កុំយកអី គ្នាស្លាប់បាត់ហើយ ។

ធានី ៖ ចាស! គ្រាន់ប្រាប់ឈ្មោះមកមីងដែលគាត់បាន?

ម៉ាច ៖ វឿន ។

ធានី ៖ ស្រីដែរ?

ម៉ាច ៖ ស្រីដែរ ស្លាប់បាត់ហើយ បើមិនឃើញមកស្រុកផង ។

ធានី ៖ ហើយអ្នកណាគេទៀត មីងថាមាន៣នាក់?

ម៉ាច ៖ ៣នាក់នឹងធ្វើការជាមួយខ្ញុំ ។

ធានី ៖ មីងផង ហើយនឹង២នាក់ទៀត?

ម៉ាច ៖ អឺ! មានស្រួយមួយដែរ ។

ធានី ៖ គាត់នៅរស់ទេ?

ម៉ាច ៖ នៅរស់ ប៉ុនឥឡូវនៅស្រុកមោង (មោងឬស្សី ខេត្តបាត់ដំបង) ។

ធានី ៖ កាលពេលមីងទៅនឹង មីងទៅខ្លួនឯង ឬមួយក៏មានអ្នកណាគេប្រាប់អីដែរ?

ម៉ាច ៖ ចូលធ្វើការនឹង?

ធានី ៖ ចាស! ដូចថាគេមកបង្ខំមីង ឬមួយក៏មីងស្ម័គ្រចិត្តទៅខ្លួនឯង?

ម៉ាច ៖ គេមកបង្ខំ បើកុំគេហៅអ្នកណាចង់ទៅធ្វើអីចឹង១ បើមិនដឹងអីសោះ ។

ធានី ៖ គេមកហៅ?

ម៉ាច ៖ អឺ!គេមកហៅទៅគេមកហៅឲ្យយើងចូលធ្វើនឹង យើងមានទៅដឹងអីចង់ទៅធ្វើអីចឹង បើមិន ដឹងអីសោះ ។

ធានី ៖ ហើយបើមីងមិនទៅ បើទៅម៉េច?

ម៉ាច ៖ បើគេហៅយើងទៅហើយ បើយើងមិនទៅ ខ្លាចគេធ្វើបាបយើងនឹង ។

ធានី ៖ គេធ្វើបាបម៉េចទៅ?

ម៉ាច ៖ យើងខ្លាចទៅបើសូម្បីតែកងកុមារ ក្នារត់មកលេងផ្ទះនឹង នៅតែគេចាប់ចងវ៉ៃដឹក្នា នឹកម៉ែ រត់មកលេងម៉ែនៅតែចាប់ចងក្នាវ៉ៃដឹ ។

ធានី ៖ មីងស្គាល់?

ម៉ាច ៖ មិនទេ មិនមែនខ្ញុំទេ ខ្ញុំឃើញ ប៉ុនខ្ញុំដឹង ហើយពុកម៉ែគេយកទៅកងប្រមូលផ្តុំ នឹកម៉ែគេរត់ មកលេងផ្ទះ គេតាមមកចាប់ទៅអស់វ៉ៃក្នា ។

ធានី ៖ ហើយអ្នកណាគេអ្នកវ៉ៃកូនក្មេងនឹង?

ម៉ាច ៖ គេ១មេប្រធាននឹង ប្រធានកុមារគេនឹង មានប្រធានកុមារគេនឹង ។

ធានី ៖ ឈ្មោះគាត់ទេ?

ម៉ាច ៖ ស្គាល់ឈ្មោះ នៅខាងជើង ។

ធានី ៖ ឈ្មោះអីគេមីង?

ម៉ាច ៖ ឈ្មោះ ណៃ ។

ធានី ៖ គាត់នឹងប្រធានកុមាររាល់ថ្ងៃ?

ម៉ាច ៖ អត់ទេ! ប្រធានជំនាន់នឹង ។

ធានី ៖ ប៉ុន្តែ គាត់រស់នៅរាល់ថ្ងៃ?

ម៉ាច ៖ នៅកាលនឹងមិនដឹងនៅណាទេ អត់ដែលឃើញនៅស្រុកនេះទេ ។

ធានី ៖ មិនមែននៅស្រុកយើងនេះទេ?

ម៉ាច ៖ ម៉ែឪវានៅស្រុកនឹង តែគេអត់នៅស្រុកនឹងទេ ។

ធានី ៖ នៅភូមិណាដែរមីង?

ម៉ាច ៖ នៅភូមិព្រៃលៀបនឹងដូចតែគ្នា ។

ធានី ៖ គាត់ឈ្មោះអីណៃ?

ម៉ាច ៖ មិនដឹងឈ្មោះអី ឈ្មោះណៃនឹង មិនដឹងតាគេឈ្មោះអី ខ្ញុំវានៅស្មើរដែរ ស្គាល់តែឈ្មោះគេនឹង ដឹងតាគេឈ្មោះអី បើឪគេស្គាល់ ។

ធានី ៖ ហើយអីចឹងដល់ពេលមីងឃើញគេវ៉ៃកុមារផ្ទាល់ភ្នែកអីចឹង មីងមានអារម្មណ៍?

ម៉ាច ៖ យើងអារម្មណ៍ យើងមិនភ័យ យើងមិនខ្លាចៗខ្លួនយើងដែរ ដល់ធ្វើអីចឹងៗយើងមិនខ្លាច ខ្ញុំអត់ចង់ស្លាប់ ចង់រស់ ។

ធានី ៖ បន្ទាប់ពីពេលមីងឃើញអីចឹង ក៏មីងតាមគេតាមឯងទៅដែរ ហើយទៅតែ៣នាក់នឹងទេ ម៉ាភូមិមីងនឹង ហើយមានអ្នកផ្សេងទៅទៀត?

ម៉ាច ៖ តែ៣នាក់នឹង គេហៅខ្ញុំចូលធ្វើពេទ្យតែ៣នាក់នឹង ។

ធានី ៖ ចុះអ្នកផ្សេងទៀតអត់មានទេ?

ម៉ាច ៖ អត់ទេ មានតែអ្នកមកពីឆ្ងាយៗមកៗនៅនឹង មកនៅធ្វើពេទ្យ ។

ធានី ៖ ខាងណា?

ម៉ាច ៖ គេស្រុកក្រោម ។

ធានី ៖ គេមកធ្វើពេទ្យនៅនឹង ឬមួយក៏គេចាត់តាំងឲ្យមក?

ម៉ាច ៖ គេអង្គការគេចាត់តាំងឲ្យមកនៅជាមួយយើង ។

ធានី ៖ មកនៅជាមួយមីងដែរ?

ម៉ាច ៖ ព្រោះយើងអ្នកពួកថ្មី គេអ្នកចេះចាស់ យើងថ្មី ដូចគេមកបង្រៀនយើងអីចឹងកាលមកនៅជាមួយយើងនឹង ។

ធានី ៖ មីងស្គាល់ឈ្មោះពួកគាត់ទេ ដែលគាត់មកបង្រៀនមីង?

ម៉ាច ៖ គាត់ស្លាប់បាត់អស់ហើយពួកអស់នឹង ឈ្មោះអីដល្លីមួយ ឈ្មោះរ៉ែមអីចឹងទៅ ប៉ុនមិនដឹងនៅស្រុកណាទេ រ៉ែមមួយ ដល្លីមួយ ហ្នឹងគេចុះមកបង្រៀនយើង ពួកយើងថ្មីៗក្មេងមិនចេះមិនដឹងអីនោះ គ្រាន់ថាគេប្រធានយើងហើយ ប៉ុនមិនដឹងនៅស្រុកណាទេ មិនសូវដឹងទេ ។

ធានី ៖ ពេលបង្រៀននឹង បង្រៀនម៉េចខ្លះ?

ម៉ាច ៖ គេបង្រៀនយើងចាក់នឹង ។

ធានី ៖ គេបង្រៀនចាក់ម៉េច?

ម៉ាច ៖ បង្រៀនយើងចាក់ថ្នាំនឹង ។

ធានី ៖ ទៅដល់ភ្លាមគេប្រាប់យើងម៉េចខ្លះ បានយើងអាច?

ម៉ាច ៖ អឺ! គេបង្រៀនយើងឲ្យចាក់ថ្នាំឲ្យអ្នកជម្ងឺនឹង បើយើងអត់ចេះគេមិនបង្រៀនយើង ត្រង់ណាសាច់ដុំ ត្រង់ណាសាច់មិនដុំ គេប្រាប់យើងអីចឹង យើងចេះរៀនៗតាមគេទៅ ។

ធានី ៖ រៀនម៉េចខ្លះ?

ម៉ាច ៖ មានរៀនអក្សរអី ប៉ុនគ្រាន់ថារៀនឲ្យចាក់អីចឹង សាច់ដុំអីចឹងទៅ ថ្នាំនេះ ថ្នាំនោះ យើងឈឺនេះចាក់អានេះ ឈឺនោះចាក់អានោះ គេគ្រាន់បង្រៀនយើងអីចឹង ហើយយើងចេះតាមគេទៅ យើងតូច ។

ធានី ៖ ហើយកាលនឹងមីងរៀនអីចឹង ចេះទេ?

ម៉ាច ៖ មានអី ប៉ុនទាល់តែមានគេធំតាមដែរ គេធំទៅគេប្រាប់ អ៊ីនេះថ្នាំនេះយើងចាក់ទៅ គេធំគេប្រាប់ណា ។

ធានី ៖ ចុះដំបូងធម្មតាយើងអត់ចេះអីចឹង យើងធ្វើម៉េចយើងត្រូវសាក់ជាមួយអីសិនឬមួយក៏ទៅ ដល់បង្រៀនជាមួយអ្នកគេ?

ម៉ាច ៖ អ្នកគេចេះនឹងគេបង្រៀនម៉ុង ។

ធានី ៖ គេបង្រៀនជាមួយអ្នកជម្ងឺផ្ទាល់ម៉ុង?

ម៉ាច : ហ្នឹងហើយបង្រៀនជាមួយអ្នកជម្ងឺផ្ទាល់ម៉ង អ្នកជម្ងឺឈឺអីចឹងគេនាំ គេហៅយើងទៅ២នាក់ ប្រាប់ឯងចាក់ថ្នាំនេះឲ្យគាត់អីចឹង ចាក់ត្រឹមសាច់ដុំត្រឹមនេះ ហើយយើងចាក់តាមគេទៅ ។

ធានី : តែដំបូងយើងដូចជាធម្មតាមនុស្សយើងអីចឹង មិនសូវចេះកាន់ម្ជុរចេះអី ធ្វើម៉េចអីម៉េច ដូចជាមីងធ្វើផ្ទាល់ ពេលដែលមីងពេលបង្រៀនដំបូង គេឲ្យទៅដល់ភ្លាមទៅចាក់ម៉ង ឬមួយ ក៏រៀន២-៣ថ្ងៃសិន ឬម៉េចអីចឹង?

ម៉ាច : គេមាននៅកន្លែង អ្នកជម្ងឺក្នុងកន្លែង ឲ្យយើងបង្រៀនក្នុងកន្លែង ។

ធានី : រៀនបណ្តើរចាក់បណ្តើរ?

ម៉ាច : រៀនបណ្តើរម៉ង ។

ធានី : រៀននឹងរៀនប៉ុន្មានថ្ងៃ?

ម៉ាច : ដូចរាប់ថ្ងៃមិនបាន បើរាល់ថ្ងៃ ។

ធានី : រាល់ថ្ងៃ?

ម៉ាច : អឺ! គេដើរជាមួយយើង ។

ធានី : នៅឃុំនឹងរហូត?

ម៉ាច : នៅពេទ្យឃុំ ។

ធានី : នៅប៉ុន្មានខែប៉ុន្មានថ្ងៃ?

ម៉ាច : ពេទ្យឃុំនឹងប្រហែលជិត២ឆ្នាំ ចុះអាពតមិនដល់២ឆ្នាំ តែគ្រាន់ថាជិត៣ឆ្នាំជាង ៣ឆ្នាំប៉ុន្មាន បានគេហៅទៅភ្នំពេញទៅ គេហៅទៅភ្នំពេញទៅភ័យព្រលឹងចុងសក់ មិនដឹងគេយកទៅណា

ធានី : ពេលគេហៅនឹង?

ម៉ាច : ពេលគេហៅនឹងភ័យណាស់ ភ័យ.....ដឹងម៉ែនឹងគាត់ភ័យជំនួសកូនទៅវ៉ៃចោល ភ័យដឹង ដំណឹងវិលមកវិញបានគាត់ដឹង ។

ធានី : ដល់ពេលមីងរៀននៅពេទ្យឃុំនឹង អ្នកណាគេជាប្រធានរបស់មីង?

ម៉ាច : មានដល្លីនឹង បងដល្លី និង វ៉ែមនឹង តែ២នាក់នឹងមិនដឹងមកពីស្រុកណាទេ ។

ធានី : គាត់២នាក់នឹងមកបង្រៀនមីង ហើយធ្វើប្រធានរបស់មីង?

ម៉ាច : ហ្នឹងហើយនៅប្រធាននៅនឹងម៉ង ។

ធានី : ប្រធានឃុំ?

ម៉ាច : ប្រធានពេទ្យៗនៅក្នុងនឹង មិនមែនប្រធានឃុំ ប្រធានពេទ្យ ។

ធានី ៖ ពេលដែលមីងនៅនឹង មីងបានឃើញអីខ្លះ អ្នកជម្ងឺមកពីណាពីណែ?

ម៉ាច ៖ អ្នកជម្ងឺតែឃុំយើងនឹងៗ ប្រជាជននៅឃុំយើងនឹង ។

ធានី ៖ ហើយមីងព្យាបាលយ៉ាងម៉េច?

ម៉ាច ៖ គេណែនាំយើងជម្ងឺចេះចោះ ព្យាបាលថ្នាំនេះថ្នាំនោះ យើងមើលគេតាមគេ ។

ធានី ៖ ថ្នាំអីខ្លះទៅមីងដែលគេព្យាបាល?

ម៉ាច ៖ ថ្នាំស្រុកយើងគ្មានស្អីទេ បើថ្នាំធ្វើខ្លួនឯងមានថ្នាំអាចម៍ទន្សាយ ថ្នាំខ្យល់ អាចម៍ទន្សាយ ថ្នាំចុក ជីខ្វី ម្រេចហ្នឹង ថ្នាំយើងធ្វើខ្លួនឯង ។

ធានី ៖ មីងចេះធ្វើដែរ?

ម៉ាច ៖ កាលនឹងគេឲ្យធ្វើ កាលគេឲ្យធ្វើថ្នាំនឹង យើងពេទ្យនឹង គេឲ្យស្ងួថ្នាំ ។

ធានី ៖ យើងជាពេទ្យ យើងធ្វើថ្នាំខ្លួនឯង?

ម៉ាច ៖ ហ្នឹងហើយធ្វើថ្នាំខ្លួនឯងខ្លះ មិនមែនចេះអត់ទេ ធ្វើបានថ្នាំមួយមុខ ពីរមុខនឹងទេ ។

ធានី ៖ ថ្នាំអីខ្លះមីង ២មុខនឹង?

ម៉ាច ៖ បានតែថ្នាំចុកពោះ ខ្យល់ហ្នឹង ។

ធានី ៖ អាចម៍ទន្សាយនឹង?

ម៉ាច ៖ រាគអាចម៍ ។

ធានី ៖ ហើយនឹងថ្នាំអីគេទៀត?

ម៉ាច ៖ តែប៉ុននឹង ។

ធានី ៖ តែមួយមុខនឹង តែថ្នាំមួយនឹង?

ម៉ាច ៖ ចា៎ស! តែថ្នាំអស់នឹង ។

ធានី ៖ ហើយថ្នាំនឹងគេធ្វើម៉េចខ្លះ គេធ្វើពីអីខ្លះ បានចេញថ្នាំហ្នឹង?

ម៉ាច ៖ ថ្នាំនឹងច្រើនដែរ មានគាសន្តមកិច្ចៗគាត់រៀបថ្នាំឲ្យស្ងួ ថ្នាំស្ងួយើងមិនចេះទេ អ្នកអត់ដឹង មានគាសន្តមកិច្ច តែឥឡូវគាត់ស្លាប់ហើយគាមិចៗនឹង គាត់រកឫសឈើនឹងមក ឲ្យយើងរំងាស់ ដល់យើងរំងាស់ទៅយកទឹកជាតិវា ហើយនឹងម្សៅៗមី ជីខ្វី យើងហាល យើងលាយឲ្យម៉ត់ យើងកិនឲ្យម៉ត់ទៅ ហើយយើងលុញធ្វើជាថ្នាំនឹងទៅ ។

ធានី ៖ អីចឹងធាតុផ្សំរបស់វាមានម្សៅមី ហើយឫសឈើនឹងមានអីខ្លះ?

ម៉ាច ៖ ឫសឈើនឹង មានជីខ្វី ។

ធានី ៖ មានជីខ្វី ហើយអីទៀត?

ម៉ាច ៈ បើមានម្រេចដាក់ម្រេច ។

ធានី ៈ ម្រេចម៉េច?

ម៉ាច ៈ ម្រេចយើងនឹងហូបនឹង ។

ធានី ៈ ម្រេចយើងហិល ៗ ?

ម៉ាច ៈ ហើយគេមានផ្លែកំចាត់កំចាយ ផ្លែកំចាត់កំចាយនឹងយកមកលីងមក ព្រោះវាហិល ។

ធានី ៈ ផ្លែនឹងម៉េចទៅ?

ម៉ាច ៈ តូចៗ ខ្ញុំវាចង់ភ្លេចហើយផ្លែនឹងតូចៗនឹង ផ្លែកំចាត់កំចាយនឹងវាហិលៗរិលទៅវាដេញខ្យល់ដែរ បានតែប៉ុននឹងខ្លួនឯង ។

ធានី ៈ អានឹងថ្នាំខ្យល់ដែរ?

ម៉ាច ៈ ថ្នាំខ្យល់ ថ្នាំចុកពោះនឹង មានប៉ុននឹងធ្វើខ្លួនឯង ។

ធានី ៈ អានឹងថ្នាំនឹងវាចេញមករូបរាងវាម៉េច?

ម៉ាច ៈ អានឹងយើងធ្វើយើងលុញខ្លួនឯងទេ យើងសូនខ្លួនឯង ម៉្យាយើងកិនលីងកិនខ្លួនឯងធ្វើខ្លួនឯង ។

ធានី ៈ វាពណ៌អីគេ?

ម៉ាច ៈ ខ្មៅ យើងលីងឆ្អិនទៅជាខ្មៅនឹង យើងលីង ហើយដល់ក្រោពីនឹងមានថ្នាំសូដូចបើកពីពេទ្យស្រុកមក ។

ធានី ៈ ថ្នាំសូម៉េចទៅ?

ម៉ាច ៈ ថ្នាំសូ ថ្នាំចាក់អីសុទ្ធបើកពីពេទ្យស្រុក ឃុំធ្វើមិនកើត ។

ធានី ៈ ថ្នាំសូនឹងម៉េច?

ម៉ាច ៈ ទេ! មិនដឹងជាសូយ៉ាងម៉េចថ្នាំនឹងដូចមិនសុទ្ធម៉េច យើងអត់ដឹងដែរ យើងដឹងតែដល់ពេលទៅបើក ។

ធានី ៈ តែថ្នាំនឹងគេសូ?

ម៉ាច ៈ ដាក់ដបដូចដបទឹកក្រូចពីដើមៗ ដូចដបទឹកក្រូចយើងឥឡូវជំនាន់នឹង ។

ធានី ៈ គេដាក់ដបទឹកក្រូច?

ម៉ាច ៈ ដបទឹកក្រូច មានថ្នាស៊ិចគេស្រោបជាប់កៅស៊ូរិត ។

ធានី ៈ អានឹងហៅថ្នាំអីគេថ្នាំសូនឹង?

ម៉ាប : ថ្នាំស្ងួនឹងគេចាក់ទៅត្រដាក់ក៏បាន បុកក៏ត្រូវ ជម្ងឺឈឺឆ្អឹងឆ្អែងក៏បាន តែគេមានឈ្មោះគេ តែខ្ញុំវាមិនចេះអក្សរមិនសូវចាំ មានឈ្មោះគេ ។

ធានី : តែដូចមីងអត់ចេះអក្សរអី ធម្មតាថ្នាំមួយៗគេបិទផ្លាក?

ម៉ាប : គេបិទផ្លាក ។

ធានី : ធ្វើម៉េចមីងដឹងថាអានឹងថ្នាំអីៗ?

ម៉ាប : ចាំដែរ ចំណាំដែរ ចំណាំឈ្មោះបានដែរ ដូចថាកង់ហ្វូគេសរសេរដកង់ហ្វូនៅនឹងដឹងថាដបថ្នាំ ឈ្មោះកង់ហ្វូ ដបមួយឈ្មោះបេអង់ គេដាក់អក្សរនៅនឹងទៅ ។

ធានី : ប៉ុន្តែមីងធ្វើម៉េចដឹងថាអានឹងបេអង់ អានឹងកង់ហ្វូ?

ម៉ាប : ចំណាំដែរ ។

ធានី : ចំណាំយ៉ាងម៉េច?

ម៉ាប : ចំណាំអក្សរគេនៅនឹងដែរ ។

ធានី : អក្សរម៉េចអានឹងគេហៅអី?

ម៉ាប : ហ្នឹងហើយ ។

ធានី : ចុះបើថ្នាំច្រើនធ្វើម៉េចមីងចំណាំអស់ទៅ?

ម៉ាប : គ្មានច្រើន ថ្នាំតែ២-៣មុខ ។

ធានី : អីខ្លះទៅ?

ម៉ាប : ថ្នាំជំនាន់នឹងគ្មានអី ។

ធានី : មិញមីងប្រាប់ខ្ញុំមាន?

ម៉ាប : មានកង់ហ្វូ បេអង់ គីនីន ។

ធានី : មានអីទៀតទេ?

ម៉ាប : ស្អីទេមួយមុខទៀតទេ មានតែ៣មុខ ។

ធានី : ហើយថ្នាំនឹងគេយកប្រើសម្រាប់ឈឺអីខ្លះ?

ម៉ាប : ថ្នាំនឹងសម្រាប់តែ បើគីនីនថ្នាំគ្រុននឹងក្តៅគ្រុនចាក់ទៅគីនីននឹង អានឹងបើក្តៅយើងគ្រុន ហើយបើបេអង់នោះ កាលណាយើងចុកពោះនាយអាយយើងខ្យល់អីនឹងឆ្អឹងឆ្អែងនឹងកង់ហ្វូ ក៏ចាក់បានដែរមិនអីទេ ប៉ុនបើចាក់ទៅវាមិនគ្រោះថ្នាក់អ្នកជម្ងឺដែរ វាគ្រាន់ថាអាឈឺៗម៉ាស្រាលៗងើបមិនងើបមិនសូវដឹងទេ តែវាអត់មានគ្រោះថ្នាក់ទេ ។

ធានី ៖ ស្អីទេ អាឈើស្រាលៗ ងើបមិនងើប?

ម៉ាច ៖ អា យើងមិនឈឺធ្ងន់នឹងណា យើងដឹងថាយើងចាក់ទៅងើបតិចក៏មិនដឹង ធ្ងន់ក៏មិនដឹង បើថាអ្នកជម្ងឺសួរទៅសុទ្ធតែធួរៗ ។ ខ្ញុំពិបាកដែរអីចឹង បានថាពិបាកណាស់អ្នកជម្ងឺ យើងវាឈឺអីចឹង អាណាខ្លះគ្នាទៅធ្វើការធ្វើឈឺទៅចឹងទៅ ដល់ហើយយើងពិបាកដែរនឹង មិនដឹងជាគិតម៉េចនឹងនេះកើត បើធ្វើតាមដំណើរទៅ បើយើងគេប្រាប់ឲ្យចាក់អាណា ចាក់អានឹងទៅ យើងមិនសូវដឹង ដូចកូនក្មេង ។

ធានី ៖ អីចឹងមុននឹងមីងចាក់ថ្នាំ ដឹងថាត្រូវមានការប្រាប់ពីបងរ៉ែម ហើយនឹងផល្លីសិន សិនបានមីងចាក់បាន ហើយម៉េច?

ម៉ាច ៖ ដល់មាន ហ្នឹងដល់មានគេអ្នកធំ គេចេះជាងយើងគេប្រាប់ ។

ធានី ៖ គេប្រាប់ឲ្យមីងចាក់អី បានមីងអាចចាក់បាន?

ម៉ាច ៖ បានហ៊ានចាក់កើត ។

ធានី ៖ ចុះបើសិនជាគាត់អត់នៅ មីងធ្វើម៉េចអ្នកជម្ងឺមួយគំនរ?

ម៉ាច ៖ មិនទេ គេមិនចោលទេ បើទៅមួយនៅមួយ ។

ធានី ៖ កាលនឹងមីងដឹងថាថ្នាំដែលមីងរៀបរាប់ប៉ុន្មាន៣-៤មុខ មីងថាថ្នាំស្ល ហើយធ្វើម៉េចដឹង?

ម៉ាច ៖ ថ្នាំគេចំហ៊ុយនឹង មានថ្នាំចំហ៊ុយម៉ង ។

ធានី ៖ ធ្វើម៉េចបានដឹងថាគេផ្សំពីអីៗខ្លះទៅ?

ម៉ាច ៖ អត់ដឹង ថ្នាំយើងយកពីគេមិនដឹង ។

ធានី ៖ យកពីខាងណាមកវិញ?

ម៉ាច ៖ យកពីស្រុក ។

ធានី ៖ ស្រុកណា?

ម៉ាច ៖ កន្លែងពេទ្យស្រុក ។

ធានី ៖ ពេទ្យស្រុក?

ម៉ាច ៖ ពេទ្យស្រុកគេ ពេទ្យស្រុកនេះ ។

ធានី ៖ មានស្គាល់អ្នកនៅពេទ្យស្រុក?

ម៉ាច ៖ មិនស្គាល់ មិនដឹងគេនៅស្រុកណាស្រុកណែ មិនស្គាល់ទេ ដឹងតែថាយើងតូចជាងគេ ដឹងគេប្រើឲ្យទៅបើកថ្នាំទៅហើយ ។

ធានី ៖ ៣នាក់ជិះទៅខ្លួនឯង?

ម៉ាច :　ហ្នឹងហើយ ខស្សាហ៍ទៅដែរ ។

ធានី :　ទៅបើកពីណាគេ?

ម៉ាច :　បើអានឹងពេទ្យស្រុកគេ គីរី ។

ធានី :　ឈ្មោះអីគេ?

ម៉ាច :　មិនស្គាល់គេទេ មិនស្គាល់ពេទ្យគេ មិនស្គាល់ៗឈ្មោះ យើងវានៅតូចផង មិនសូវស្គាល់គេ ។

ធានី :　ដល់គេឲ្យធ្វើ?

ម៉ាច :　អឺ! ព្រោះតែគេប្រើឲ្យទៅបើកទៅៗ កង់ជិះទៅៗ យើងអត់ស្គាល់ទេ ។

ធានី :　ពេលដែលមីងព្យាបាល មីងព្យាបាលខ្លួនឯង ឬមួយក៏ទាល់តែមាន(ស្តាប់មិនបានឮ)?

ម៉ាច :　គេបងៗប្រធានៗធំៗ(ស្តាប់មិនបានឮ) ។

ធានី :　(ស្តាប់មិនបានឮ)

ម៉ាច :　(ស្តាប់មិនបានឮ)អ្នកជម្ងឺនឹង នៅមើលថែជម្ងឺនឹងទៅ ។

ធានី :　ថែយ៉ាងម៉េច?

ម៉ាច :　ថែអ្នកជម្ងឺឈឺស្រែកឈឺអីចឹង គេមកប្រើខ្ញុំទៅចាក់ឲ្យគេអីចឹងទៅ យើងតូចជាងគេស្រេចតែគេប្រើៗ ។

ធានី :　ហើយអ្នកជម្ងឺច្រើនទេ?

ម៉ាច :　មិនសូវមានប៉ុន្មានទេ ។

ធានី :　គាត់មកពីណាវិញ?

ម៉ាច :　មកពីឃុំយើង ម៉ាឃុំ ។

ធានី :　មីងដែលធ្លាប់សួរគាត់មកពីភូមិនេះៗ ជាអ្នកណា ជាចាស់ ជាថ្មី?

ម៉ាច :　ឃុំយើង សុទ្ធងឹងភូមិ ។

ធានី :　ស្គាល់គាត់ទេ?

ម៉ាច :　ស្គាល់តើ ស្គាល់សុទ្ធតែឃុំយើង ។

ធានី :　ឈ្មោះអីខ្លះ?

ម៉ាច :　អឺ! រៀបរាប់មិនអស់ទេ មានអ្នកនៅឃុំយើងច្រើន ។

ធានី :　មានអ្នកនៅរស់ដល់រាល់ថ្ងៃ?

ម៉ាច :　អ្នកនៅក៏មាន ស្លាប់ក៏មាន ។

ធានី ៖ លើកម្នាក់ ២នាក់មក?

ម៉ាច ៖ អ្នកស្លាប់ក៏មាន អ្នករស់ក៏មាន ជម្ងឺច្រើន ដូចជាយាយតាម៉ាន់នឹងវ៉ាន់គាត់មិនទាន់ស្លាប់ទេ គ្រាន់គាត់អ្នកធ្លាក់ឈាម ឥឡូវនៅរបស់គាត់ យាយនឹងឈ្មោះអីទេ ប៉ុនខ្ញុំមិនសូវស្គាល់ទេ ខ្ញុំមិនសូវចាំ ។

ធានី ៖ ពេលដែលអ្នកភូមិព្យាបាលនៅកន្លែងគាត់នឹង លុះត្រាតែមានការប្រាប់ពីបងវ៉ែម និងផល្លី នឹង បានយើងចាក់ថ្នាំឲ្យគេ?

ម៉ាច ៖ លុះតែគេប្រើ ។

ធានី ៖ គេប្រើ បើគេអត់ប្រើមីងអត់ធ្វើទេ?

ម៉ាច ៖ គេប្រើ គេឈឺយើងមិនដឹង យើងមិនហ៊ានទេ យើងមិនដឹង យើងមិនចេះ យើងមិនដឹង ទាល់តែគេប្រើ ។

ធានី ៖ មីងថាមីងរៀនពេទ្យដែរ?

ម៉ាច ៖ មិនដែលរៀនណា៎ ។

ធានី ៖ អត់ទេ ប្រាប់ថាគេបង្រៀបមីង បង្រៀនចាក់ម៉េច?

ម៉ាច ៖ អឺ! បង្រៀនឲ្យចាក់នឹង ពីដំបូងយើងអត់ទាន់ចេះនោះ ។

ធានី ៖ ចុះមីងចេះព្យាបាល?

ម៉ាច ៖ អឺ! មិនដឹងព្យាបាលម៉េច អត់សូវចេះ បើគេប្រើឲ្យចាក់ទៅ ។

ធានី ៖ នៅបាន ចាក់បាន?

ម៉ាច ៖ ឲ្យចាក់អីចាក់នឹងទៅ ។

ធានី ៖ ប៉ុន្តែព្យាបាលខ្លួនឯងអី?

ម៉ាច ៖ មិនចេះទេ មិនដឹងទេ ។

ធានី ៖ ចុះពេលណាគេឲ្យទៅមីងនិយាយថា គេឲ្យមីងទៅភ្នំពេញ ហើយឪពុកម្ដាយមីងភ័យ?

ម៉ាច ៖ ដល់នៅតាមឃុំហើយ គេឲ្យយើងទៅលើឃុំៗ(ស្ដាប់មិនបានខ្យល់) ហើយម្នាក់មិនឃើញ ទេ ខ្ញុំថាស្លាប់ ។

ធានី ៖ ឈ្មោះអីគេ?

ម៉ាច ៖ ខ្ញុំហៅតែរឿនៗ ។

ធានី ៖ អូ! រឿននឹង?

ម៉ាច ៖ រឿនហ្នឹង ។

ធានី ៖ មីងចាំឆ្នាំទេ កាលនឹងឆ្នាំណាដែលគេហៅមីងទៅភ្នំពេញ?

ម៉ាច ៖ គ្មានដឹងឆ្នាំប៉ុន្មានទេ អត់ដឹងទេ អត់ចេះដឹងឆ្នាំដឹងខែទេ ។

ធានី ៖ ហើយគេហៅមកម៉េច អ្នកណាមកហៅ គេហៅទៅធ្វើអី?

ម៉ាច ៖ ពួកភូមិ មេឃុំនឹងគេប្រាប់ម៉ង គេប្រាប់ថានេះឯងត្រូវទៅលើ២នាក់អានេះ ពីរនាក់អា រឿនហ្នឹង មិនដឹងទៅលើទៅណាទេ យើងអត់ដឹងដឹងតែគេថាប្រាប់ទៅលើអីចឹង ។

ធានី ៖ ហើយទៅដល់ណា?

ម៉ាច ៖ ភ្នំពេញ ដល់ហើយឡានគេមកយកអីចឹង ។

ធានី ៖ មានតែមីង២នាក់ទេ?

ម៉ាច ៖ ទៅតែ២នាក់ ម៉ាឃុំនឹងគេឲ្យទៅតែ២នាក់ ។

ធានី ៖ ប៉ុន្តែមានអ្នកផ្សេងទៅជាមួយមីងមានទេ?

ម៉ាច ៖ អត់មាន ទៅតែ២នាក់ ម៉ាឃុំ២ៗគេដកម៉ាឃុំ២ ។

ធានី ៖ ម៉ាឃុំ២ តែឃុំផ្សេងៗ២ៗដែរ?

ម៉ាច ៖ ២ដែរ ។

ធានី ៖ ទៅប៉ុន្មាននាក់ទៅមីង?

ម៉ាច ៖ អឺ! ច្រើនដែរ ពុតែគេហៅក្រៅៗឃុំយើងមិនស្គាល់គេៗ ក្រៅៗភូមិឃុំយើងមិនស្គាល់ គេ ច្រើនដែរ៨-១០នាក់ដាងដែរ យើងមិនស្គាល់គេ ក្រៅៗឃុំយើងអត់ស្គាល់ ដូចនៅ ស្មើរដែរ យើងអត់ស្គាល់ យើងនៅស្មើរ ។

ធានី ៖ ហើយពេលដែលមីងទៅដល់នោះ ម៉េចទៀតទៅ ទៅដល់ភ្នំពេញម៉េចអីខ្លះ?

ម៉ាច ៖ ទៅដល់ភ្នំពេញគេឲ្យនៅកន្លែងពេទ្យ៦មករា ។

ធានី ៖ ទៅដល់ភ្លាមចូលពេទ្យ?

ម៉ាច ៖ នៅនឹង ចូលនៅនឹង គេដឹកដាក់នឹង ។

ធានី ៖ ហើយម៉េចទៀត?

ម៉ាច ៖ ដល់ដាក់នឹងអីចឹងទៅ គេបង្រៀនយើងឲ្យចេះព្យាបាលអ្នកជម្ងឺចេះទៅ ។

ធានី ៖ បង្រៀនម៉េចខ្លះ?

ម៉ាច ៖ បង្រៀនឲ្យយើងចេះលាងរបួស រុំរបួសរុំអីចឹងទៅ បើយើងមិនចេះ យើងមិនដឹង ធ្វើត្រូវ ក៏ត្រូវ យើងធ្វើមិនត្រូវគេកសាងយើងទៅ គេស្តីយើងទៅ ។

ធានី ៖ គេស្តីដែរ?

ម៉ាច ៖ គេស្តីៗដែរ យើងមិនសូវចេះ មិនសូវដឹង គេស្តីល្មមម៉ាទឹកភ្នែករបស់គេដែរ យើងមិនសូវចេះ តាំងគ្នាតូចៗ ។

ធានី ៖ ខាងណាគេបង្រៀនមីង ឈ្មោះអី?

ម៉ាច ៖ មិនស្គាល់គេទេ នៅភ្នំពេញនឹងមិនស្គាល់គេទេ ។

ធានី ៖ គេអត់ប្រាប់ថាឈ្មោះអី មកបង្រៀន?

ម៉ាច ៖ អត់ មិនស្គាល់ដែរ ក៏មិនដឹងនៅស្រុកណាៗ ។

ធានី ៖ ហើយមីងទៅពេទ្យ៦មកភានឹង គេបង្រៀនពីការរុំរបួស ហើយបង្រៀនអីទៀត?

ម៉ាច ៖ ខ្ញុំមានរៀនអី មានតែរុំរបួសនឹង ហើយនឹងជម្ងឺទូទៅ មានត្រូវការព្យាបាលណា ។

ធានី ៖ គេៗសរសេរអក្សរ?

ម៉ាច ៖ គេសរសេរអក្សរដាក់ឲ្យដាក់ ប៉ុនយើងអត់ចេះ ។

ធានី ៖ អីចឹងធ្វើម៉េចដឹង?

ម៉ាច ៖ សរសេរអក្សរហើយគេនិយាយប្រាប់ទៀត គេនិយាយប្រាប់ទៀត គេនិយាយទៀត សរសេរហើយ អ្នកគេចេះគេមើលទៅ ហើយអ្នកមិនចេះគាត់ប្រាប់ដែរ និយាយប្រាប់ចេះចុះ ។

ធានី ៖ អ្នកណាគេ ស្រី ប្រុស អ្នកបង្រៀន?

ម៉ាច ៖ ប្រុសនឹង ប៉ុនមិនស្គាល់ មិននៅស្រុកយើងទេ មិនស្គាល់ ។

ធានី ៖ តែមីងធ្លាប់ឮគេហៅគាត់ឈ្មោះអីៗ ?

ម៉ាច ៖ អត់ស្គាល់ រៀនប៉ុន្មានណា៎ រៀនតែប្រហែលមិនបាន១អាទិត្យផង អស់មួយអាទិត្យ ។

ធានី ៖ បង្រៀនហើយ ធ្វើអីទៀត?

ម៉ាច ៖ រៀនហើយ ឲ្យយើងចូលធ្វើការនៅហ្នឹង ។

ធានី ៖ ចូលនៅពេទ្យហ្នឹងម៉ង?

ម៉ាច ៖ ហ្នឹងហើយ បើលាងរបួស លាងអីគេអីចឹងទៅ យើងធ្វើខុស យើងធ្វើមិនល្អ គេស្តីទៅ ។

ធានី ៖ លាងរបួសឲ្យអ្នកណាគេ?

ម៉ាច ៖ លាងរបួសឲ្យពួកអ្នកជម្ងឺគេហ្នឹង ។

ធានី ៖ អ្នកជម្ងឺពីណាគេ?

ម៉ាច ៖ អ្នកជម្ងឺកងទ័ពគេនឹង សុទ្ធតែកងទ័ព ។

ធានី ៖ អត់មានប្រជាជនយើងទេ?

ម៉ាច : មានដែរ ប្រជាជន មានជម្ងឺទូទៅទេ កង់ទ័ពគ្មានទេ កងទ័ពសុទ្ធតែទាហានហើយរបួស ជំនាន់ហ្នឹង ។

ធានី : មីងនៅពេទ្យនឹងយូរ?

ម៉ាច : នៅមិនបាន១ឆ្នាំ១ បែក ។

ធានី : ពេលដែលមីងទៅពេទ្យនឹង មានអារម្មណ៍ដូចថាម៉េចដែរ ប្លែកយ៉ាងម៉េច ខុសគ្នាយ៉ាង ម៉េច ពីយើងនៅឃុំ?

ម៉ាច : គេខុសពីឃុំ មិនដូចយើងនៅឃុំប៉ុន្មានទេ យើងនៅឃុំយើងដើរ កាលនៅនោះមិនដើរទេ នៅតែមួយកន្លែង ។

ធានី : ហេតុអី?

ម៉ាច : នៅវាឲ្យនៅមើលជម្ងឺគេតែម៉ាកន្លែងនឹង អត់ឲ្យយើងដើរណា ។

ធានី : អត់ឲ្យដើរផ្ដេសផ្ដាស់ទេ?

ម៉ាច : នៅម៉ាអគារមួយនៅនឹង១ គេអត់ឲ្យដើរ នៅតែមួយកន្លែងនឹង មើលជម្ងឺគេម៉ាកន្លែងនឹង ទៅ បើយើងនៅនោះដើរតាមភូមិតាមអីខ្វះ តាមគេតាមបង១យើងធំ១ យើងធ្វើមិន ត្រូវគេស្ដីយើង គេកសាងយើង ។

ធានី : ហើយពេលមីងនៅនឹង មីងដែលធ្លាប់ឃើញជួបរឿងចំឡែកថា ដូចថាមីងគិតថាវាមិនល្អ អីចឹង ចិត្តមីងគិតដែលធ្លាប់ឃើញ?

ម៉ាច : មិនឃើញ មិនដែលឃើញមានអីផង មិនដែលមានអីផង មិនល្អម៉េច មិនដឹងផង ។

ធានី : របៀបដូច ពេលដែលគាត់ទៅមានអ្នកជម្ងឺម្នាក់អីចឹង គាត់ឈឺយើងអត់អើពើ ឬអ្នកផ្សេង គេមិនអើពើ មិនខ្វល់ខ្វាយ ឬក៏អ្នកនឹងមើលទៅយ៉ាប់ពេក រៀបចំដាក់ថ្នាំដាក់អីខុសឬម៉េច ធ្លាប់មានទេ?

ម៉ាច : មីងអត់ដឹង ។

ធានី : អត់ដែលធ្លាប់ដឹង?

ម៉ាច : អឺ! អត់ដែលធ្លាប់ដឹង ។

ធានី : តែពេលនឹងមីងទៅដល់មីងព្យាបាលខ្លួនឯង ឬមួយក៏មានគេប្រាប់ ដូចកាលនៅពេទ្យឃុំ ដែរ?

ម៉ាច : មានគេប្រាប់ដែរ មុនដំបូងមានគេប្រាប់ មានគេដើរតាមឲ្យយើងដើរតាមគេដែរ គេឲ្យ យើងមើលគេដែរ មានប្រធានគេឲ្យយើងដើរមើលដែរ មុនដំបូង ។ ដល់យូរ១ទៅគេ

លែង គេដឹងថាយើងធ្វើកើត គេលែងទៅ។ បើកើត ធ្វើមិនកើត ក៏នៅតែខុស គេប្រជុំ
កសាង យើងយំទឹកភ្នែករហាមដដែល ។

ធានី : អ្នកណាគេអ្នកកសាងមីង?

ម៉ាច : មានប្រធានគេនឹងណា យើងមិនស្គាល់ទេ យើងនៅតូចជាងគេ មិនស្គាល់ទេ ។

ធានី : គាត់មកពីខាងណាវិញ?

ម៉ាច : គេមិនដឹងខាងណាទេ យើងមិនស្គាល់ទេ គ្មានស្គាល់អាណាមួយទេ ដឹងតែ២នាក់ទៅពីនឹងទៅ គ្មានស្គាល់គេសោះ ។

ធានី : ទៅដល់ដូចថាមីងធ្វើរបៀបម៉េច បានគេកសាងមីង?

ម៉ាច : យើងធ្វើខុសដូចយើងរុំរបួសមិនល្អ យើងលាងរបួសជម្ងឺមិនល្អមិនកើតអីចឹង គេស្តីទៅ គេប្រជុំគេកសាងយើងទៅ គេស្តីយើងទៅ យើងធ្វើការមិនល្អ ។

ធានី : អីចឹងមីងក្រៅពីការងាររលាងរបួស អត់មានព្យាបាលមានអីទៀតទេ?

ម៉ាច : គ្មានអីទេ អត់មានធ្វើអីទៀតទេ មានតែប៉ុននឹង ។

ធានី : មានតែធ្វើការលាងរបួស?

ម៉ាច : ហ្នឹង១ ។

ធានី : ក្រៅពីនឹងអត់មានធ្វើអីផ្សេង?

ម៉ាច : អត់ដែលមានធ្វើអីផ្សេង ។

ធានី : ចុះមីងដែលធ្លាប់ឃើញដូចថានៅក្នុងនឹងធ្លាប់មានអ្នកណាគេទុកអ្នកជម្ងឺចោល ឬក៏អីមានទេមីង?

ម៉ាច : អត់ដែរ មិនដែលដើរ មិនដែលដឹង ។

ធានី : ចុះនៅកន្លែងមីងផ្ទាល់នឹង ដូចថាមានគេ មីងដែលធ្លាប់ឮរឿងខុសសីលធម៌អី?

ម៉ាច : អូ! ថាខុសសីលធម៌ មិនដែលឮសួរ អត់ដែលឮគេនិយាយផង ។

ធានី : ចុះមានដែលគេប្រជុំកសាងរឿងនឹងអីមានដែលមាន?

ម៉ាច : មិនដែល អូ!បើប្រជុំកសាងមិនដែលឮសួរទេរឿងនឹង ។

ធានី : នៅក្នុងពេទ្យនេះ មីងដែលឃើញអ្នកផ្សេងអី?

ម៉ាច : អត់ មិនដែលឃើញទេ អត់ដែរ មិនដែលឮ ខ្ញុំវានៅតូចដែរក៏មិនសូវដឹងពិបាកណាស់នៅ ក្មេងគ្មានដឹងអីទេ មិនសូវដឹងនៅក្មេងពេក តែចំណាស់នឹងហើយនៅមិនសូវដឹង ។

ធានី : អីចឹងពេលមីងនៅនឹងដឹងចូលនៅនឹង ស្គាល់ឈ្មោះមន្ទីរពេទ្យ អ្នកណាជាអ្នកប្រាប់មីងរឿងឈ្មោះថា៣-៦មករាអី?

ម៉ាច : ឮសួរតែគេហៅពេទ្យ៦មករា។អីចឹងចេះតែហៅតាមគេទៅ។

ធានី : ចុះដឹងអ្នកណាគេប្រធានពេទ្យនឹងទេ?

ម៉ាច : មិនដឹងអ្នកណាប្រធាន បើមិនស្គាល់គេ គ្មានស្គាល់អ្នកណាមួយ។

ធានី : គេអត់មានប្រាប់គេឈ្មោះអី។ ធ្វើអី។ អត់ដែរ?

ម៉ាច : អត់។

ធានី : ហើយមីងនៅនឹងអង្គុយតែលាងរបួស ក្រៅពីការងារនឹង បន្ទាប់មកទៀតមានគេឲ្យមីងធ្វើអីផ្សេង។ ឬក៏ទៅកន្លែងណាកន្លែងណែ?

ម៉ាច : គ្មានឲ្យទៅណាផ្សេងទេ ឲ្យយាម តែយប់ឡើងយាម យាមបើមានផ្លាស់គ្នាម្តងម្នាក់ទៅ។

ធានី : យាមនឹង យាមម៉េច?

ម៉ាច : គេឲ្យយាមមើលជម្ងឺ អ្នកណាឈឺ អ្នកណាឈឺស្រែក អ្នកណារើអីនឹង បែបយាមត្រឹមនឹងអី បើយើងនៅតូចដែរ មិនដឹងស្អីទេ គេឲ្យយាមចេះតែយាម មិនដឹងស្អីទេ។

ធានី : អត់ដឹងគេឲ្យយាម។ម៉េច?

ម៉ាច : ឲ្យយាមចេះយាម យាមកំណត់ម៉ោងគេ ម៉ាម៉ោង២ម៉ោងម្នាក់អីចឹងទៅ ឲ្យយាមចេះយាម ហើយបើចប់ម៉ោងមិនដឹងអីទៀតទេ កសាងចង់ងាប់យើងនៅតូចយើងវាមិនដឹងអីកសាង យើង។វាមិនដឹងអីនៅតូចពេក គេអ្នកធំ។គេចេះគេដឹង យើងតូចយើងមិនចេះមិនដឹង។

ធានី : ហើយមីងកសាង។ច្រើនដងទេ ឬក៏កសាងប៉ុន្មានដង ដែលមីងនិយាយកសាងញឹកញាប់?

ម៉ាច : កសាង៣-៤ដង គេរាល់គ្នាមិនដែល តែខ្ញុំមួយ គេធ្វើមិនកើត។

ធានី : ៣-៤ដងនឹងមួយខែ ឬម៉េច?

ម៉ាច : ២-៣ខែ ១ខែម្តង២ដង ប៉ុនយូរគេប្រជុំម្តង។

ធានី : អីចឹងពេលប្រជុំម្តង។ គេនាំគ្នាកសាង?

ម៉ាច : កសាងអាងតែយើងតូច យើងធ្វើមិនកើតដូចគេធំ អាងយើងខ្លាចគេ គេកសាងយើងបានយើងមិនដែលហ៊ានធ្វើថាគេ គេធំ។

ធានី : ចុះក្រៅពីមីងមានអ្នកផ្សេង ដែលអត់ចេះអក្សរដូចមីង ហើយតូច។អីចឹងទេ?

ម៉ាច : មិនបានសួរពួកវាខ្លះទេ គ្នាច្រើនប៉ុនយើងមិនបានសួរមិនដឹងចេះ។ យើងមិនហ៊ានសួរគេ។

ធានី ៖ ប៉ុន្តែមានតូចៗដូចមីងច្រើន?

ម៉ាច ៖ មិនសូវមានទេ មានតូចតែពីខ្ញុំទៅនឹងតូចជាងគេតែខ្ញុំ គេសុទ្ធតែធំៗ ។

ធានី ៖ អីចឹងអត់?

ម៉ាច ៖ អឺ!

ធានី ៖ ហើយភាគច្រើនមីងមើលទៅឃើញពួកគាត់ចេះអក្សរអត់?

ម៉ាច ៖ ពួកគេសុទ្ធតែចេះ មិនចេះតែខ្ញុំយ៉ាង បើខ្ញុំមិនដែលបានហ៊ានសួរគេ ដែលដឹងថារបស់គ្នាខ្ញុំទៅពីនឹងទៅដឹងរៀននឹង ។

ធានី ៖ តែពេលដែលគេបង្រៀន គេមានសួរទេ ថាអ្នកណាគេចេះអក្សរខ្លះ?

ម៉ាច ៖ គេមិនសួរ គ្រាន់តែគេ ។

ធានី ៖ គ្រាន់គេប្រាប់?

ម៉ាច ៖ គេគ្រាន់សរសេរអក្សរហើយ គេពន្យល់មាត់គេប្រាប់ គេមិនសួរ ។

ធានី ៖ ពេលមីងរៀនអីចឹងយល់ច្រើនទេ?

ម៉ាច ៖ មិនសូវយល់ទេ ។

ធានី ៖ គេបង្រៀនពេទ្យម៉េច មីងអត់សូវយល់?

ម៉ាច ៖ មិនសូវយល់ទេ ខួរតិចណាស់ ។

ធានី ៖ កាលនឹងយល់ម៉េចខ្លះ ពេលដែលគេបង្រៀន?

ម៉ាច ៖ គេបង្រៀនមិនសូវយល់ម៉ង មិនសូវយល់នឹងគេទេ ខួរក្បាលតិចណាស់ តូចៗនឹងធ្លាប់រៀនពីតូចរៀនមុខភ្លេចក្រោយៗភ្លេចមុខ រៀនមិនដឹងដែរ មិនចេះទេ ។

ធានី ៖ មីងដឹងថាមូលហេតុអីបានគេឲ្យមីងមកធ្វើការខាងនឹងអត់?

ម៉ាច ៖ មិនដឹង បើគេសួរថាចេះអក្សរទេ ថាមិនចេះទេ គេមិនរើសទៅវាស្រួល ។

ធានី ៖ គេអត់សួរ?

ម៉ាច ៖ អឺ! គេអត់សួរ គេមិនសួរ ។

ធានី ៖ ចុះពេលដែលមីងធ្វើពេទ្យនឹង គេមានធ្លាប់ធ្វើប្រវត្តិរូបមីង?

ម៉ាច ៖ កាលនឹងអត់ដែលសួរទេ តែចេញពីភូមិទៅ(ស្តាប់មិនបានខ្យល់) ទៅដល់នោះគេមិនសួរ ។

ធានី ៖ ពីភូមិយើងគេសួរហើយ?

ម៉ាច ៖ គេយកភូមិយើង ឯកសារពីភូមិទៅក៏មិនដឹង ទៅដល់នោះគេអត់សួរ ។

ធានី ៖ គេអត់សួរពីយើងទៀតទេ គេឲ្យយើងចូលធ្វើការ ហើយរៀន?

ម៉ាច : គេយកយើងទៅតែម្តង ។

ធានី : ក្រៅពីកន្លែងដែលមីងចូលព្យាបាលរបួស ហើយនឹងលាងរបួសលាងអីអត់មានកន្លែងផ្សេង ដែលយើងត្រូវធ្វើការទៀតទេ នៅពេទ្យ?

ម៉ាច : អត់ទេ នៅតែកន្លែងនឹង មិនបាន១ឆ្នាំផង ប្រហែលកន្លះឆ្នាំ វៀតណាមចូលទៅ ។

ធានី : ចូលទៅដល់ក្នុងនឹងម៉ង ហើយម៉េច?

ម៉ាច : កន្លែងវៀតណាមនឹងចូល គ្មានទាន់ចូលគេជម្លៀសម៉ោង៦ចេញឲ្យផុតពីទីក្រុងភ្នំពេញ អីចឹង នាំគ្នាចេញមក អត់ទាន់មានឃើញវៀតណាមណា ។ គេឲ្យចេញ យើងម៉េចហ៊ានទៅ យើងចេញ ចេញទាំងអស់គ្នា ចេញទៅគេឲ្យជិះរថភ្លើង មកចុះនៅវ៉ាបាត់ដំបង ។

ធានី : សុំកាត់បន្តិច កន្លែងមិញ មីងថាកសាងនឹង មីងខុសអីខ្លះបានគេហៅទៅកសាងនឹង?

ម៉ាច : ថាឯងរុំមិនល្អ ឯងលាងរបួសមិនល្អ អីចឹងយើងធ្វើមិនល្អ ។

ធានី : ហើយមីងមានធ្លាប់ប្រាប់ពួកគាត់វិញ ថាមកពីយើងមិនសូវយល់ មិនសូវចេះ?

ម៉ាច : មិនហ៊ានប្រាប់គេ យើងខ្លាចគេ ។

ធានី : គេប្រាប់អីចឹងហើយម៉េចយើងធ្វើម៉េចទៀត?

ម៉ាច : ដល់ក្រោយបានគេថាយើងធ្វើមិនល្អអីចឹង យើងធ្វើក្រោយ យើងចេះខំប្រឹងគេទៅ បើ យើងខ្លាចគេកសាងហើយ ។

ធានី : អីចឹងខំប្រឹងធ្វើ?

ម៉ាច : ហ្នឹងហើយខំប្រឹងធ្វើទៅកុំឲ្យគេកសាងយើង កុំឲ្យគេស្តីយើងទៀត ។

ធានី : តែមីងក្រៅពីការកសាង គេអត់មានធ្វើអីទៀតណា កសាងគ្រាន់គេស្តីឲ្យយើង អត់មាន ធ្វើ អីផ្សេងទៀត?

ម៉ាច : អត់ទេ តែគេកសាងគេស្តីឲ្យអីចឹងស្តីឲ្យហើយទៅ ។

ធានី : អត់មានអ្នកណាដែលធ្វើខុសអីចឹង គេធ្វើយ៉ាងម៉េចទៀត ក្រៅពីកសាងស្តីឲ្យ ធ្លាប់មាន?

ម៉ាច : បើខ្ញុំមិនដឹង មិនឃើញ ។

ធានី : ដល់ពេលប្រជុំកសាងស្តីឲ្យម្តងៗ ស្តីឲ្យតែមីង ក្រៅពីមីងអត់មានអ្នកផ្សេងត្រូវបានគេ កសាងដូចមីង?

ម៉ាច : បើគេសុទ្ធតែធ្វើល្អគេមិនស្តី បើខ្ញុំនេះមិនកើត អត់ល្អ ។

ធានី : តែម្នាក់មីងទេ ក្រៅពីមីងមានពីណាគេ?

ម៉ាច ៈ ២-៣ដង គេស្ដី២-៣ដង ទឹកភ្នែក២-៣ដងម្នាក់ឯង យើងតូចជាងគេ ធ្វើការមិនល្អឲ្យគេ ។

ធានី ៈ ក្រៅពីនឹងអត់មានអ្នកណាគេត្រូវបានគេស្ដីឲ្យ?

ម៉ាច ៈ មានគេធំៗ គេគ្មានអ្នកណាស្ដីឲ្យទេ ។

ធានី ៈ អ៊ីចឹងពេលមីងរត់ទៅដល់បាត់ដំបងហើយ ពេលណាបានត្រឡប់មកដល់ស្រុកវិញ?

ម៉ាច ៈ មកដល់បាត់ដំបងយូរណាស់ទម្រាំហ៊ានចូលស្រុក ចូលខាងនោះកំពង់ចាម បងប្អូនទៅដឹកដំឡូងកំពង់ចាម មកជាមួយបងប្អូនអ្នកស្រុកដឹកដំឡូង ។

ធានី ៈ ឆ្នាំប៉ុន្មានមីងមកដល់ស្រុកវិញ?

ម៉ាច ៈ មិនដឹងឆ្នាំប៉ុន្មានទេ កាលយើងបែកឆ្នាំប៉ុន្មាន ៧៨ ៧៩ យើងបែកនឹងវៀតវ៉ៃរយចូលកំពង់ឆ្នាំងនេះ មកចូលស្រុកកំណើតមកដល់សព្វថ្ងៃទៅ ។

ធានី ៈ កាលនឹងមីងបោះឆ្នោតហើយនៅ?

ម៉ាច ៈ មកបោះឆ្នោតនឹងហើយ យើងនៅស្រុកនឹងហើយបោះឆ្នោតនឹង មកនៅស្រុកនឹងយូរពេក មកតាំងពីយូរមក គ្រាន់បែកភ្នំពេញភ្លាមស្វែងមករកចូលផ្ទះគេមក ។

ធានី ៈ ខ្លាចគេ?

ម៉ាច ៈ ខ្លាចតើមិនដឹងហ៊ានចូលណា មិនដឹងចូលណា ទើបចូលដើរកាត់ព្រៃនឹងបងប្អូនខេត្តកំពង់ឆ្នាំងនឹង មកដឹកដំឡូងគ្រប់ មកជាមួយបងប្អូនមកៗបងប្អូនគេហៅមកៗ បានចូលស្រុកតាំងពីនឹងមករហូត ទល់សព្វថ្ងៃនឹងមក ។

ធានី ៈ ដូចមីងធ្លាប់ធ្វើពេទ្យ ចំពោះចិត្តមីងផ្ទាល់ តើមីងនៅមានបំណងចង់ធ្វើពេទ្យទៀតអត់ចង់ទេ?

ម៉ាច ៈ ខួរក្បាលតិចពេក អត់ចង់ ។

ធានី ៈ អត់ចង់?

ម៉ាច ៈ វាអត់ចេះអត់ចាំ (ស្ដាប់មិនបានខ្យល់) មិនចូលចិត្តខ្ញុំមិនចេះសោះ អានឹងគេចេះហៅយើងមកធ្វើអ៊ីចឹង មកទៅអត់មាននឹកឃើញ គ្មានអារម្មណ៍សោះ ។

លក្ខិណា ៈ មីងដែលមានព្រួឈ្មោះឌុចទេ?

ម៉ាច ៈ ឌុចនឹង អត់ដែលព្រួទេ ទើបព្រួក្នុងកាសែតរាល់ថ្ងៃនេះ ។

លក្ខិណា ៈ ដឹងថាឌុចនឹងអ្នកណាគេ?

ម៉ាច ៈ មិនដែលស្គាល់ផង ។

លក្ខិណា ៖ មីងឮផ្សាយថាឌុចនឹងពីណាគេ?

ម៉ាច ៖ មិនដែលដឹងឮសួរតែឌុចៗ ស្តាប់វិទ្យុរាល់ថ្ងៃ មិនដឹងមុខគាត់ម៉េច មិនដឹងគាត់នៅណាអត់ដឹងឮសួរឈ្មោះរាល់ថ្ងៃនឹង ។

លក្ខិណា ៖ មីងដែលឮថាមានគុកទួលស្លែងមានអី?

ម៉ាច ៖ ទើបឮសួរឥឡូវនឹង ដឹងឥឡូវនឹងថាឌុចនឹងនៅគុកទួលស្លែងៗ មិនដែលស្គាល់ទេ ។

លក្ខិណា ៖ ហើយគុកទួលស្លែងនឹងគេធ្វើអីខ្លះ មីងដែលដឹងទេ?

ម៉ាច ៖ មិនដែលដឹងសោះ មិនដឹងនៅណា ។

លក្ខិណា ៖ ឌុចនឹងប្រធានគុកទួលស្លែង ។

ម៉ាច ៖ ឮតែគេផ្សាយវិទ្យុ ស្តាប់វិទ្យុរាល់យប់ ។

លក្ខិណា ៖ ហើយទួលស្លែងនឹង ប្រហែលស្លាប់មនុស្ស១ម៉ឺននាក់ជាងនៅនឹង(ស្តាប់មិនបានឮ) ។ ឌុចនឹងឥឡូវគេឃុំឃាំងគាត់តែមិនទាន់ចេញប្រកាសថាគាត់ជាប់ទោស(ស្តាប់មិនបានឮ) មីងដឹងថា នៅតុលាការនឹងគេឃុំឃាំងប៉ុន្មាននាក់អីទេ?

ម៉ាច ៖ សួរខ្ញុំដូចជាសួរ មិនដឹងទេ ដឹងរាល់ថ្ងៃស្តាប់ផ្សាយវិទ្យុ ឪវាពូកែចូលចិត្តស្តាប់ណាស់ ឮប៉ុន្មានយប់នឹង ថាឌុចៗនឹង ។

លក្ខិណា ៖ ហើយមានដឹងថាមានតុលាការកាត់ទោសមេខ្មែរក្រហមអីទេ?

ម៉ាច ៖ ថាឮតែសួរមោត់ផ្សាយតាមវិទ្យុនឹង ថាត្រង់ណាៗមិនដែល កាត់ត្រង់ណាអីត្រង់ណាក៏មិនដែលផ្សាយវិទ្យុនឹង ។

លក្ខិណា ៖ នៅតុលាការនឹងគេបង្កើតឡើងនៅឆ្នាំ២០០៦ តុលាការនឹងគេកាត់ទោសតែមេដឹកនាំខ្មែរក្រហមមេដឹកនាំជាន់ខ្ពស់ ហើយនឹងអ្នកទទួលខុសត្រូវខ្ពស់បំផុតនឹង តុលាការនឹងកាត់ទោសអ្នកប៉ុននឹង ។ ហើយរាល់ថ្ងៃនេះ មានឃុំឃាំង៥នាក់មានឌុច, អៀង សារី, អៀង ធារិទ្ធ នួន ជា, ខៀវ សំផន មាន៥នាក់នឹង ឌុចគេកាត់ហើយ នៅតែប្រកាសៗថាគាត់ជាប់ទោស ឬរួចខ្លួន តែ៤នាក់គេស៊ើបអង្កេត គេអត់ទាន់កាត់ក្តីទេ ។ មីងយល់ម៉េចដែរចំពោះការបង្កើតតុលាការ តុលាការកាត់ក្តីនឹង?

ម៉ាច ៖ មិនដឹងថាម៉េចទេ មីងមិនសូវចេះនិយាយអីចឹង ។

លក្ខិណា ៖ (ស្តាប់មិនបានឮ)

ម៉ាច ៖ មិនដឹងថាម៉េច មិនចេះនិយាយទេ អីចឹងបានថាមីងមិនចេះនិយាយ និយាយមុខភ្លេចក្រោយៗភ្លេចមុខ មិនសូវដឹងទេ ។

លក្ខិណា ៖ មីងដែលឮពាក្យប្រល័យពូជសាសន៍?

ម៉ាច ៖ ឮថាប៉ុលពត ប្រល័យពូជសាសន៍ៗ ឮតែថាអីចឹងដែរ ។

លក្ខិណា ៖ ឮថាអីចឹង មីងយល់ម៉េចដែរ ពាក្យនឹងមានន័យ?

ម៉ាច ៖ ប្រល័យពូជសាសន៍ៗ ប៉ុលពតប្រល័យពូជសាសន៍ ។

ធានី ៖ មីងនឹងគុកទួលស្លែងមនុស្ស ១ម៉ឺននាក់ជាងដែលចូលទៅក្នុងនឹងហើយ ដែលចូលដឹងថាស្លាប់ ហើយឌុចនឹងគាត់ប្រធាន មីងគិតថាគេស្នើឲ្យគាត់ជាប់ទោស៤០ឆ្នាំ នឹង មីងគិតថាការស្នើ សុំនឹងម៉េចដែរ តិចពេក ច្រើន ល្មម?

ម៉ាច ៖ ឌុចនឹងសម្លាប់ច្រើនអីចឹងម៉េច?

លក្ខិណា ៖ នៅគុកទួលស្លែងនឹងគេអត់សម្លាប់មនុស្សទេ គេធ្វើតែទារុណកម្មទេ កន្លែងសម្លាប់ជើងឯកផ្សេងទៀត តែគាត់នឹងប្រធានគុកទួលស្លែង ។ តើមីងគិតថា មនុស្សស្លាប់១ម៉ឺននាក់ ជាងជាប់ទោស៤០ឆ្នាំ តិច ល្មម ឬក៏ច្រើនមីង?

ម៉ាច ៖ ៤០ឆ្នាំ?

លក្ខិណា ៖ ចា៎ស!ជាប់ទោស៤០ឆ្នាំ ឥឡូវគាត់អាយុ៦០ជាងហើយ ។

ម៉ាច ៖ អឺ! គាត់ចាស់ហើយ គាត់នៅ៤០ឆ្នាំទៀត ។

លក្ខិណា ៖ មីងគិតថាទោសនឹងម៉េចដែរ?

ម៉ាច ៖ បើគាត់អាយុចាស់សន្ធឹកដែរ ប៉ុននឹងដែលល្មមគាត់ហើយ ចាស់ជិត៧០ហើយ ។

លក្ខិណា ៖ ហើយមីងគិតថាការបង្កើតតុលាការនឹងល្អចំពោះកូនចៅជំនាន់ក្រោយទេ?

ម៉ាច ៖ ល្អហើយ កុំឲ្យកូនយើងជំនាន់ក្រោយៗនៅនឹកឃើញ បើជំនាន់ខ្ញុំងាប់ កូនក្មេងឥឡូវវាដឹងហើយ កូនខ្ញុំរាល់ថ្ងៃ ខ្ញុំប្រាប់រាល់ថ្ងៃ «កូនអើយខំប្រឹងប្រែងរៀនសូត្រឲ្យចេះដឹង កុំឲ្យល្ងិតល្ងង់ដូចម៉ែ ម៉ែកាលជំនាន់គេប្រើ ម៉ែល្ងង់មិនដឹងអីទេ គេប្រើតាមគេបង្គិល ម៉ែល្ងិតល្ងង់ ហើយកូនឯងកើតជំនាន់រាល់ថ្ងៃនេះ ជំនាន់ទំនើបហើយ មិនមែនជំនាន់ម៉ែទេ ម៉ែខាអាវស្លៀករកមិនបានទេ កូនឯងស្លៀកម៉ាសេរី» ខ្ញុំប្រាប់«ខំប្រឹងប្រែងរៀន ធ្វើការរកស៊ីឲ្យចេះដឹងនឹងគេ កុំឲ្យដូចម៉ែ» ខ្ញុំបង្រៀនកូនរាល់ថ្ងៃតែអញ្ចឹង កុំឲ្យដូចម៉ែ «ម៉ែល្ងិតល្ងង់ហើយ កើតជំនាន់កំសត់ទៀត (ស្លាប់មិនបានខ្យល់)» ។ ប្រដៅកូនអីចឹងសព្វថ្ងៃ ដឹងថាម៉ែនឹងវាកើតមកចំជំនាន់ល្ហេមល្ហាមទៅហើយ មិនដឹងធ្វើម៉េច កុំឲ្យកូនក្រោយៗកុំធ្វើដូចម៉ែ កុំឲ្យល្ងិតល្ងង់ដូចម៉ែ ។

លក្ខិណា ៖ តុលាការនឹង មីងគិតថាផ្តល់យុត្តិធម៌ជូនមីងទេ គេរកយុត្តិធម៌ឲ្យមីងទេ តុលាការកាត់ទោសនឹង?

ម៉ាច ៖ ការកាត់ទោសនឹង ។

លក្ខិណា ៖ ចុះមីងគិតថាការបង្កើតមិញលួ តើគេអាចរកយុត្តិធម៌ឲ្យមីងទេ ចំពោះការឈឺចាប់ដែលមីង ឆ្លងកាត់ក្នុងសម័យនឹង?

ម៉ាច ៖ មីងមិនយល់ទេ មីងមិនសូវយល់ទេ ។

លក្ខិណា ៖ (ស្តាប់មិនបានខ្យល់) អៀង ធារិទ្ធប្រធានសង្គមកិច្ច ប្រធានពេទ្យ ដែលឃើញមុខគាត់ទេ អ្នកកាន់កាប់ខាងសង្គមកិច្ច ខាងពេទ្យ ខាងសាលារៀនអី អៀង ធារិទ្ធ ។ មីងដែលឃើញមុខគាត់ មីងទៅពេទ្យនឹង?

ម៉ាច ៖ អញមិនដែលឃើញទេ ឮសូរតែអៀង សារី, អៀង ធារិទ្ធ មិនដែលស្គាល់មុខម៉េច ។

លក្ខិណា ៖ ធ្លាប់ឮដែរ?

ម៉ាច ៖ ឮអៀង សារី, អៀង ធារិទ្ធ ឮតែថាអីចឹង មិនដឹងឈ្មោះមុខម៉េច ។

លក្ខិណា ៖ ក្នុងសម័យនឹងឮដែរ ឬម៉េចមីង?

ម៉ាច ៖ ឮឥឡូវ ឮតែអីចឹងដែរ ។

លក្ខិណា ៖ ឮឥឡូវនឹង នេះប្តីគាត់អៀង សារី, ហើយនេះខៀវ សំផន ។ ពួកគាត់អាយុច្រើនៗហើយ ខ្ទះ៨០ ខ្ទះ៧០ជាង ហើយឈឺទៀត ។

ម៉ាច ៖ ឮតែតាខៀវ សំផនៗ ឮតែឈ្មោះអីចឹង ។

លក្ខិណា ៖ ហើយការកាត់ទោសនឹងយូរទម្រាំស៊ើបអង្កេតបាន បើថាគាត់ស្លាប់មុនពេលគេកាត់ទោសគាត់អីចឹង អាចរកយុត្តិធម៌ឲ្យមីងដដែល ទើបនឹងស្លាប់បាត់ទៅមុនពេលគេកាត់ទោសគាត់?

ម៉ាច ៖ ពិបាកណាស់ មិនដឹង មិនចេះទេ ។

លក្ខិណា ៖ ចុះពាក្យយុត្តិធម៌មានន័យថាម៉េចដែរ?

ម៉ាច ៖ ខ្ញុំវាពិបាក ដឹងគិតឃើញថាមិនត្រូវ និយាយមិនកើត ។

លក្ខិណា ៖ អីចឹងអរគុណច្រើនមីង ដែលបានចំណាយពេលឲ្យពួកខ្ញុំសម្ភាសន៍ ។

«ចប់»